# **មតិសំណេះសំណាល**

## **ថ្លែងដោយ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា**

## **ក្នុងពិធីប្រគល់ "ជ័យលាភីអាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន - និស្សិតពូកែ"**

### **ជូនសិស្សានុសិស្សថ្នាក់មធ្យមសិក្សាទូទាំងប្រទេស**

**សាលសន្និសីទ ចតុមុខ ព្រឹកថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៧**

សូមគោរព **គណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !**

សូមគោរព **បណ្ឌិត ហារុហ៊ីសា ហាន់ដា** ប្រធានមូលនីធិអន្តរជាតិដើម្បីសិល្បៈ និង វប្បធម៌ នៃ ទីក្រុងតូក្យូ - ប្រទេសជប៉ុន និង ជាអធិការបតី នៃ សាកលវិទ្យាល័យកម្ពុជា !

សូមគោរព **ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និង ក្មួយៗទាំងអស់ !**

ជាបឋម ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកបណ្ឌិត **ហារុហ៊ីសា ហាន់ដា (Haruhisa Handa)** អ្នកដឹកនាំអង្គការ World Mate ប្រធាន និង ស្ថាបនិកមូលនីធិអន្តរជាតិ ដើម្បីសិល្បៈ និង វប្បធម៌នៃ ទីក្រុងតូក្យូ-ប្រទេសជប៉ុន និង ជាអធិការបតី នៃសាកលវិទ្យាល័យកម្ពុជា ដែលជានិច្ចកាល តែងផ្តល់ការគាំទ្រដល់វិស័យអប់រំថ្នាក់ឧត្តមសិក្សាកម្ពុជា ជាពិសេសគឺ ការឧបត្ថម្ភ អាហារូបករណ៍ពេញថ្លៃ (១00%) ចំនួន ៥00 កន្លែង ជូនដល់សិស្សានុសិស្សថ្នាក់ទី១២ ទូទាំងប្រទេស ដែលបានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និង បានទទួលនិទ្ទេសល្អ ក្នុងឆ្នាំសិក្សា ២00៦-២00៧ នេះ ។

ម្យ៉ាងវិញទៀត សូមសរសើរ សាកលវិទ្យាល័យកម្ពុជា (UC) ដែលតែងយកចិត្តទុកដាក់ដល់ការ លើកស្ទួយគុណភាពអប់រំថ្នាក់ឧត្តមសិក្សា និង ការអភិវឌ្ឍធនធាននិស្សិត និង យុវជន ដើម្បីរួមចំណែក កសាង និង អភិវឌ្ឍប្រទេសជាតិយើង អោយបានរួចផុតពីភាពក្រីក្រ និង បានរុងរឿងទៅអនាគត។

ក្នុងឱកាសនេះដែរ ខ្ញុំសូមអរគុណដល់សាកលវិទ្យាល័យកម្ពុជា និង បណ្ឌិត **ហារុហ៊ីសា ហាន់ដា** ដែលបានប្រសិទ្ធិនាមអាហារូបករណ៍នេះថា " **អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន - និស្សិតពូកែ** " ។

**ឯកឧត្តម លោកជំទាវ អស់លោក ~ លោកស្រី !**

ថ្ងៃនេះ ខ្ញុំមានមនោសញ្ចេតនារំភើបរីករាយ ដោយបានចូលរួមជាប្រធានគណៈអធិបតីក្នុងពិធីប្រគល់ “**ជ័យលាភីអាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន ~ និស្សិតពូកែ**” ចំនួន ៥០០ កន្លែង ដើម្បី ជូនដល់សិស្សានុសិស្ស ថ្នាក់មធ្យមសិក្សាទូទាំងប្រទេស ។

ខ្ញុំសូមថ្លែងអំណរគុណដល់ មាតាបិតា និង អាណាព្យាបាល ក៏ដូចជាសិស្សានុសិស្សថ្នាក់ទី១២ ទូទាំងប្រទេស ដែលទើបនឹងប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ **(Bac II)** ឆ្នាំសិក្សា ២០០៦-២០០៧ ដែលបានអញ្ជើញមកទទួលប័ណ្ណអាហារូបករណ៍នេះ ។

តទៅនេះ ខ្ញុំសូមមានមតិ និង ជូនយោបល់ខ្លះៗចំពោះក្មួយៗ ដែលជាអ្នកទទួលបានអាហារូបករណ៍នេះ :

## I- ខ្ញុំ សូមលើកសំណួរថា :

- អ្វីទៅជាអាហារូបករណ៍ ?
- តើអាហារូបករណ៍ មានសារៈសំខាន់យ៉ាងណា ?
- តើសិស្សបែបណា ដែលអាចទទួលអាហារូបករណ៍បាន ?
- តើអាហារូបករណ៍អាចជួយផ្តល់ ដល់និស្សិតខ្មែរ ពិសេស គឺនិស្សិតក្រីក្រនូវឱកាស និង លទ្ធភាពសិក្សា នៅថ្នាក់សាកលវិទ្យាល័យ ដូចម្តេច ?

☞ ពាក្យថាអាហារូបករណ៍ (តាមទស្សនៈរបស់ខ្ញុំ) គឺមានអត្ថន័យសំខាន់ណាស់ ចំពោះសិស្សានុសិស្ស ដែលគ្មានលទ្ធភាព និង ឥតធនធានក្នុងការរៀនសូត្រ ។ ក៏ប៉ុន្តែ បើគ្មានភាពឈ្លាសវៃ គ្មានភាពឧស្សាហ៍ព្យាយាម គ្មានការតស៊ូប្តូរផ្តាច់ខិតខំរៀនសូត្រទេ នោះគេពុំអាចទទួលបានអាហារូបករណ៍ ចប់ចុងចប់ដើម និង សម្រេចជោគជ័យ ក្នុងការសិក្សារបស់ខ្លួនបានទេ ។

ជាការពិតណាស់ អាហារូបករណ៍ តែងផ្តល់ផលល្អសំរាប់តែសិស្សពូកែ - សិស្សដែលហ៊ានលះបង់អ្វីៗទាំងអស់ ដើម្បីការសិក្សារបស់ខ្លួន និង សិស្សដែលអាចធ្វើវិភាគទាននូវចំណេះដឹងនោះ ជូនដល់សង្គមវិញ ទៅថ្ងៃក្រោយ ។

សាកលវិទ្យាល័យ ក៏ដូចជាអ្នកផ្តល់មូលនីធិ ដែលបង្កើតនូវអាហារូបករណ៍នេះ ក៏មានបំណងមិនខុសពីគំនិតខ្ញុំដែរ ។ គឺ យើងចង់អោយសិស្សានុសិស្សគ្រប់មជ្ឈដ្ឋាន ជាពិសេសគឺ សិស្សក្រីក្រ ដែលមកពីជនបទ បានចូលរៀនសូត្រ ក្រេបយកចំណេះដឹងបន្តទៅថ្នាក់ឧត្តម ឱ្យបានទូលំទូលាយថែមទៀត សំរាប់

អភិវឌ្ឍខ្លួនឯងផង និង អភិវឌ្ឍប្រទេសជាតិផង ។ ម្យ៉ាងទៀត គឺយើងចង់អោយនិស្សិត ក្លាយជាបញ្ញវន្តពិតៗ ដើម្បីចូលរួមចំណែកកសាងប្រទេសជាតិ និង អភិវឌ្ឍសេដ្ឋកិច្ចជាតិយើង អោយបានរុងរឿងទៅអនាគត ។

## II – **ចំណេះដឹង សេដ្ឋកិច្ច** (Knowledge Economy) :

សម័យនេះ គឺជាសម័យបច្ចេកវិជ្ជាដ៏ជឿនលឿន - ជាសម័យដែលសង្កត់ធ្ងន់ទៅលើ **"ចំណេះដឹងជាសេដ្ឋកិច្ច"** ។ បច្ចុប្បន្ននេះ ពុំមែនមានតែប្រទេសមួយ ឬ ក៏ពុំមែនមានតែប្រទេសមួយចំនួនក្នុងតំបន់ទេ គឺ បណ្តាប្រទេសទាំងអស់នៅលើពិភពលោកទាំងមូលនេះ សុទ្ធតែត្រូវការចំណេះដឹងបច្ចេកវិជ្ជាទំនើប ជាសេដ្ឋកិច្ច និង ការបណ្តុះបណ្តាលចំណេះដឹងនេះ ដើម្បីប្រឈមនឹងផលប៉ះពាល់ជាអវិជ្ជមាន នៃ "សាកលភាវូបនីយកម្ម" លើគ្រប់វិស័យនៃ ប្រទេសជាតិនោះ ។

ដូច្នេះ ក្មួយៗត្រូវតែខិតខំ ស្រវាស្រទាញរៀនសូត្រ ក្រេបយកចំណេះដឹងនេះអោយបាន ដើម្បីយកធ្វើជាចំណេះដឹងសេដ្ឋកិច្ចរបស់ខ្លួន និង ដុសខាត់វាអោយទៅជាចំណេះដឹងពិត ឬ ចំណេះធ្វើ **(Know How)** អោយស្របតាមតម្រូវការទីផ្សារពលកម្មក្នុងស្រុក ក្នុងតំបន់ និង លើពិភពលោក។

## III – ***ការសិក្សានៅសាកលវិទ្យាល័យ ខុសពីការសិក្សានៅថ្នាក់មធ្យមសិក្សា :***

☞ ក្មួយៗត្រូវកត់សំគាល់នូវភាពខុសគ្នានៃការសិក្សានេះ អោយបានច្បាស់លាស់ ដូចខាងក្រោម:

### **១. ភាពខុសគ្នា នៃ ល្បឿនរៀនសូត្រ :**

នៅថ្នាក់ឧត្តមសិក្សា ឬ សាកលវិទ្យាល័យ ការសិក្សាមានល្បឿនលឿនណាស់ - វាទាមទារអោយមានការអានសៀវភៅច្រើន - វាទាមទារអោយចេះប្រើពេលវេលារៀនសូត្រ អោយមានប្រសិទ្ធភាពខ្ពស់ ;

**២.** សិស្សត្រូវតែឆ្ងល់ - ត្រូវតែសួរគ្រូ - ត្រូវតែហ៊ានបញ្ចេញមតិពិភាក្សា ទៅតាមការយល់ដឹងរបស់ខ្លួន ។ កាលណាសិស្សមិនសួរគ្រូ - សិស្សគ្មានចម្ងល់ ឬ គ្មានមតិទេ គ្រូនៅថ្នាក់សាកល វិទ្យាល័យយល់ថា **"សិស្សចេះអស់ហើយ"** តែផ្ទុយទៅវិញ សិស្សគ្មានចេះអ្វីទាំងអស់ ។

ដូច្នេះ និស្សិតថ្នាក់សាកលវិទ្យាល័យ ត្រូវតែហ៊ានសួរ ហ៊ានដេញដោល ហ៊ានបញ្ចេញមតិ ហ៊ានវិភាគបញ្ហាជាមួយគ្រូ ដោយក្លាហានបំផុត ។ និស្សិតត្រូវធ្វើអោយដូចពាក្យចាស់ថា **" បើចង់ចេះ អោយសម្លាប់អាចារ្យ បើចង់បានផ្លែផ្កា អោយយកភ្លើងដុតគល់"** ។

**៣. ការទទួលខុសត្រូវលើការសិក្សា ពុំមែនស្ថិតនៅលើ គណៈសាស្ត្រាចារ្យ មាតាបិតា ឬ អាណាព្យាបាលទេ :**

គឺស្ថិតនៅលើក្មួយៗ - គឺខ្លួនយើងនេះហើយ ដែលជាអ្នកទទួលខុសត្រូវចំពោះការសិក្សា និង អនាគតរបស់យើងដោយខ្លួនយើង ។ រីឯមាតាបិតា គ្រូអាចារ្យ ឬ អាណាព្យាបាលគ្រាន់តែជាអ្នកផ្តល់កំដៅតែប៉ុណ្ណោះ ។ ដូចមេមាន់ដែលក្រាបពង គឺមេមាន់គ្រាន់តែជាអ្នកផ្តល់កំដៅ ដើម្បីជួយអោយពងមាន់នោះ ញាស់បានជាកូនមាន់តែប៉ុណ្ណោះ តែត្រង់ថាញាស់ជាកូនមាន់ល្អ ឬ ទៅជាពងមាន់ចាំសំបុកនោះ គឺអាស្រ័យទៅលើធាតុពិត របស់ពងមាន់ខ្លួនឯង ។ យ៉ាងណាមិញ ក្មួយៗក៏ដូច្នេះដែរ ដើម្បីអោយក្លាយខ្លួនជាបញ្ញវន្តពិតប្រាកដ ក្មួយៗត្រូវខិតខំសិក្សាដោយខ្លួនឯង ត្រូវខិតខំអានសៀវភៅអោយបានច្រើន - ត្រូវខិតខំធ្វើកិច្ចការ ដែលគ្រូដាក់អោយធ្វើនៅផ្ទះ **(Homework ឬ Assignment)** ត្រូវខិតខំស្តាប់-កត់ត្រា-ពិចារណាយកចំណេះដឹងរបស់គ្រូមកធ្វើជារបស់ខ្លួន (ភាវនាបញ្ញា) នោះ ទើបអាចក្លាយទៅជាអ្នកចេះដឹង និង យកចំណេះដឹងនោះ មកធ្វើជារបស់ខ្លួនដើម្បីបំរើខ្លួន និង សង្គមជាតិខ្លួនបាន ។

**៤. រៀនក្នុងថ្នាក់មួយម៉ោង ត្រូវរៀននៅក្រៅថ្នាក់បីម៉ោង :**

ជាទូទៅ ការសិក្សានៅថ្នាក់សាកលវិទ្យាល័យ ការសិក្សាក្នុងថ្នាក់ជាមួយគណៈសាស្ត្រាចារ្យមួយម៉ោង និស្សិតត្រូវស្វែងយល់សិក្សាដោយខ្លួនឯង ទៅលើមុខវិជ្ជាដដែលនោះ ពី ២ ទៅ ៣ ម៉ោងបន្ថែមទៀត ។ ធ្វើដូច្នេះ គឺដើម្បីអោយនិស្សិតកាន់តែមានការយល់ដឹងទូលំទូលាយ និង ជ្រាលជ្រៅថែមទៀត តាមរយៈការសិក្សាស្រាវជ្រាវបន្ថែមដោយខ្លួនឯង ។ ដូច្នេះហើយ និស្សិតត្រូវមានវត្តមានជាដាច់ខាតនៅក្នុងថ្នាក់ ដើម្បីក្រេបយកចំណេះដឹង និង ការណែនាំរបស់គ្រូ សំរាប់សិក្សារៀនសូត្របន្ថែមដោយខ្លួនឯង ។ បើពុំធ្វើដូច្នោះទេ នោះការសិក្សារបស់គេ នឹងគ្មានគុណភាព ។

**៥. នៅថ្នាក់មធ្យមសិក្សា គ្រូបញ្ចុកចំណេះវិជ្ជា តែថ្នាក់ឧត្តមសិក្សា និស្សិតរៀនដោយខ្លួនឯង :**

ជាការពិតណាស់ សាកលវិទ្យាល័យ តែងបណ្តុះបណ្តាលអោយនិស្សិតឈរលើគោលគំនិតរបស់ខ្លួន ដោយត្រូវរៀនបញ្ចេញមតិ - រៀនការពារមតិរបស់ខ្លួន និង រៀនសិក្សាស្រាវជ្រាវ ក្នុងការវិភាគ បញ្ហា និង រៀនតស៊ូមតិជាមួយអ្នកដទៃ **(Debate Study)** ។ រីឯ សិស្សដែលសិក្សានៅថ្នាក់មធ្យម សិក្សា គឺមានអ្នកគ្រូលោកគ្រូ នៅចាំជួយបញ្ចុកចំណេះវិជ្ជាទាំងស្រុង ពោលគឺអ្វីៗត្រូវបានបង្រៀនទាំង អស់ ផ្ទុយស្រឡះពីថ្នាក់ឧត្តម ដែលនិស្សិតត្រូវសិក្សាស្រាវជ្រាវដោយខ្លួនឯង បន្ទាប់ពីគ្រូបានបង្រៀនមុខវិជ្ជាណាមួយរួចហើយ ។ ដោយកម្មវិធីសិក្សាក្នុងថ្នាក់តិច និស្សិតសាកលវិទ្យាល័យត្រូវមានភាពឈ្លាសវៃ ខិតខំប្រមែប្រមូលពតិមានជាចំណេះដឹងអោយបានច្រើនបំផុត តាមរយៈការសិក្សាស្រាវជ្រាវ

នៅក្នុងបណ្ណាល័យ និង ការអានសៀវភៅអោយបានច្រើន ក៏ប៉ុន្តែការសិក្សានេះ ត្រូវប្រើប្រាស់ពេលវេលាអោយបានតិចបំផុត ។

### ៦. អំពីការប្រឡង និង ការទទួលពិន្ទុ :

ការប្រឡងនៅថ្នាក់សាកលវិទ្យាល័យ តិចជាងការប្រឡងនៅថ្នាក់វិទ្យាល័យ គឺមានតែការប្រឡង នៅពាក់កណ្តាលឆមាស **(Mid-term Exam)** និង ការប្រឡងឆមាសតែប៉ុណ្ណោះ ។ នៅក្នុងការប្រឡងទាំងពីរនេះ បើនិស្សិតប្រឡងធ្លាក់ការប្រឡងណាមួយហើយ និស្សិតនោះធ្លាក់ហើយ ។ ដូច្នេះសូមក្មួយៗ ប្រយ័ត្នប្រយែងបំផុត ចំពោះការប្រឡងនេះ ។

ម្យ៉ាងទៀត ចំពោះការទទួលពិន្ទុវិញ ក៏ជាការសំខាន់ណាស់ដែរ ។ បើក្មួយៗបានពិន្ទុះទាបនោះគឺក្មួយធ្លាក់ហើយ ។ ដូច្នេះ ការបន្តអាហារូបករណ៍នឹងមានការលំបាក ព្រោះអាហារូបករណ៍ទាំងឡាយតែងមានល័ក្ខខណ្ឌ័ខ្ពស់ ។ ដូច្នេះ ចូរក្មួយៗខិតខំរៀនសូត្រយកពិន្ទុអោយបានខ្ពស់បំផុត ។ សូមកុំរង់ចាំថ្ងៃស្អែកចាំរៀន ចាំអានសៀវភៅ ឬ ថ្ងៃស្អែកចាំធ្វើកិច្ចការដែលគ្រូដាក់អោយធ្វើនៅផ្ទះ **(Homework)** ។ ដូច្នេះ បើធ្វើអ្វីមួយ ក្មួយៗត្រូវធ្វើឱ្យហើយ កុំទុកឡើយបង្កើតកើ្ត **(Tomorrow Never Comes)** ។

### ៧. អំពីយុទ្ធសាស្ត្រដែលត្រូវដោះស្រាយ ក្នុងពេលរៀនក្នុងថ្នាក់ :

ប្រសិនបើក្មួយៗរៀនខ្សោយ - រៀនមិនទាន់គេ ឬ រៀនធ្លាក់ ក្មួយៗត្រូវតែស្វែងរកយុទ្ធសាស្ត្រដោះស្រាយបញ្ហានោះ អោយទាន់ពេលវេលា ។ យុទ្ធសាស្ត្រនោះគឺ :

- ត្រូវទៅជួបគ្រូ
- ត្រូវទៅជួបទីប្រឹក្សាសាលា , ឬ
- ត្រូវទៅជួបលោកនាយកសាលា ដើម្បីស្នើសុំការណែនាំរបស់គាត់ អោយយើងរៀនពូកែ ឡើងវិញ ។

### ៨. ម្នាក់ៗសុទ្ធតែមានទេពកោសល្យ រៀងៗខ្លួន :

ជាការពិតណាស់ និស្សិតយើងម្នាក់ៗ សុទ្ធតែមានទេពកោសល្យពីកំណើតរៀងៗខ្លួន ក៏ប៉ុន្តែអ្នកខ្លះ ពូកែនេះ អ្នកខ្លះពូកែនោះ ជួនពូកែដូចគ្នា ជួនពូកែមិនដូចគ្នា ។ ជួនកាល ម្តាយពូកែខាងប្រវត្តិសាស្ត្រ ឪពុក ពូកែខាងសេដ្ឋកិច្ច តែដល់បានកូនមក ពូកែខាងវិទ្យាសាស្ត្រកុំព្យូទ័រ ទៅវិញ ។ល។

ដូច្នេះ យើងត្រូវតែមើលទេពកោសល្យរបស់យើងអោយច្បាស់ មុននឹងសិក្សាជំនាញណាមួយ ។ បើយើងពូកែអ្វី យើងចូលចិត្តអ្វី យើងគួរតែសិក្សាយកមុខវិជ្ជានោះ ទើបអាចក្លាយខ្លួនជាមនុស្សជំនាញឆាប់រហ័ស និង ពិតប្រាកដ ។

## ៩. អំពីការគ្រប់គ្រងពេលវេលា :

ក្មួយៗជានិស្សិតនៅថ្នាក់ឧត្តមសិក្សា ពុំគួរបណ្តែតបណ្តោយអោយពេលវេលា កន្លងផុតទៅដោយងាយៗ ដោយពុំបានធ្វើកិច្ចការដែលគ្រូដាក់អោយធ្វើនៅផ្ទះ ឬ ដោយពុំបានរៀនក្នុងថ្នាក់ ឬ ពុំបានរៀនក្រៅថ្នាក់ ឬ ក្នុងបណ្ណាល័យទេ ។ និស្សិតពូកែ គួរតែមានផែនការច្បាស់លាស់ ក្នុងការប្រើប្រាស់ពេលវេលារៀនសូត្រប្រចាំថ្ងៃ - ប្រចាំសប្តាហ៍ - និង ប្រចាំខែ ឬ ប្រចាំឆ្នាំ។ ក្មួយៗត្រូវដឹងថា តើពេលណាក្មួយៗ ត្រូវទៅរៀនក្នុងថ្នាក់? ពេលណាទៅអានសៀវភៅ ? ពេលណានៅធ្វើការងារដែលគ្រូដាក់អោយធ្វើ ? ពេលណាទៅបន្ទប់ពិសោធន៏កុំព្យូទ័រ ? ពេលណាទៅជួបគ្រូដើម្បីសុំយោបល់ ? ឬពេលណា ទៅហាត់កីឡា ? និង ម៉ោងណា ទៅរៀនត្រៀម ? ។ល។

ដូច្នេះ ក្មួយៗត្រូវចេះបែងចែក និង គ្រប់គ្រងពេលវេលាសិក្សាអោយបានល្អបំផុត ។

ចូរកុំភ្លេចពាក្យចាស់ លោកថា « ពេលវេលាស៊ីមនុស្ស..........បើចង់កុំអោយពេលវេលាស៊ីមនុស្ស មនុស្ស ត្រូវស៊ីពេលវេលាវិញ » ។ ចាស់ៗ តែងប្រដៅ អោយយើងចេះមើលពេលវេលា :

☞ មើលពេលវេលា ដែលកន្លងផុតទៅ　　　　គ្មានពេលណានៅៗ នឹងថ្កល់ឈរយប់
　 ពេលមួយនាទី ស្មើពេជ្រមួយគ្រាប់　　　　មកប្រញាប់សូត្ររៀន ទាន់ខ្លួននៅក្មេង ។

## ១០. ត្រូវមានកម្លាំងចិត្ត និង ការប្តេជ្ញាចិត្តខ្ពស់ក្នុងការរៀនសូត្រ :

បញ្ហាដ៏សំខាន់មួយនៅក្នុងការសិក្សានោះ គឺការតាំងចិត្ត និង ការជម្រុញទឹកចិត្តអោយខិតខំសិក្សា។ បើគ្មានកម្លាំងចិត្តទេ ការប្តេជ្ញាចិត្តក៏គ្មានដែរ ។ កម្លាំងចិត្ត គឺបានមកពីក្នុងចិត្តរបស់យើង ។ ដូច្នេះហើយ ក្មួយៗត្រូវមានកម្លាំងចិត្ត និង ការប្តេជ្ញាចិត្តខ្ពស់ក្នុងការសិក្សា នោះទើបការសិក្សារបស់ យើងបានសំរេចជោគជ័យ ។

## ១១. ត្រូវមានសេចក្តីស្មោះត្រង់ក្នុងការសិក្សារបស់ខ្លួន :

រាល់ការសិក្សារបស់និស្សិត ដាច់ខាតមិនត្រូវលួចចម្លងគ្នាទេ ។ ការលួចចម្លងពីអ្នកដ៏ទៃ គឺជាការបង្អាប់បន្ថុះខ្លួនឯង ។ ការរៀនសូត្រដោយចម្លងគេ វាធ្វើអោយយើងបានពិន្ទុមែន តែធ្វើអោយល្ងង់រហូត។ សិស្សដែលលួចចម្លងគេ គឺជាសិស្សដែលបន្ទាបបន្ថោកខ្លួនឯង ។ ដូច្នេះ ក្មួយៗត្រូវមានសេចក្តីស្មោះត្រង់ក្នុងការសិក្សារបស់ខ្លួន និង ត្រូវចាំថាការរៀនសូត្របានចេះដឹងដោយខ្លួនឯង ឬ មានទ្រព្យដោយការខិតខំស្វែងរកដោយខ្លួនឯងនោះ គឺជាភាពថ្លៃថ្នូរណាស់ ។

## ១២. ត្រូវលើកស្ទួយសេចក្តីគោរព :

ដើម្បីឱ្យក្មួយៗ ក្លាយខ្លួនជាពលរដ្ឋល្អ ទៅអនាគត ក្មួយៗត្រូវ :

- គោរពគ្រូ - គោរពវិន័យសាលា - គោរពមិត្តភ័ក្តិ និង គោរពគ្នាទៅវិញទៅមក
- រៀនសូត្រជាមួយគ្នា ត្រូវរៀនគោរពគ្នា រៀនជួយគ្នា រៀនស្តាប់គ្នា និង រៀនអត់ឱនអោយគ្នា

## ១៣. និស្សិតសាកលវិទ្យាល័យ គឺជាដង្កូវចោះសៀវភៅ :

ដង្កូវដែលចោះសៀវភៅ មានភាពមមាញឹក និង តស៊ូស្វិតស្វាញយ៉ាងណា និស្សិតសាកលវិទ្យាល័យ ក៏ត្រូវមានលក្ខណៈសម្បត្តិ និង ការតស៊ូក្នុងការអានសៀវភៅយ៉ាងនោះដែរ ។ សៀវភៅ គឺជា ឃ្លាំងនៃចំណេះដឹង ។ បើនិស្សិតមិនបើកសៀវភៅទេ ចំណេះដឹងក៏មិនចេញពីសៀវភៅដែរ ។ គឺមានតែការបើកសៀវភៅ និង ការដើរតួជាដង្កូវចោះសៀវភៅទេ ដែលអាចជួយអោយក្មួយៗអាចស្វែងរកបានចំណេះដឹងទូលំទូលាយ និង សំបូរបែបបាន ។

សូមក្មួយៗ ចងចាំនូវមតិនេះ !

**ឯកឧត្តម លោកជំទាវ អស់លោក - លោកស្រី និង ក្មួយៗដែលបានទទួលអាហារូបករណ៍ ក្នុងថ្ងៃនេះ !**

ខ្ញុំសូមផ្តាំផ្ញើតែប៉ុណ្ណេះចំពោះក្មួយៗ ដែលទើបនឹងបានទទួល “ **អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន ~ និស្សិតពូកែ** ” នៅសាកលវិទ្យាល័យកម្ពុជា ។

សង្ឃឹមថា ក្មួយៗនឹងយកមតិណែនាំរបស់ខ្ញុំ ទៅពិនិត្យពិចារណា និង ប្រែក្លាយសំណូមពរទាំង នេះ អោយទៅជាកម្លាំងជម្រុញចិត្ត **(Motivation)** ដ៏ខ្លាំងក្លាមួយ សំរាប់លើកស្ទួយកម្លាំងចិត្តសិក្សា អោយសម្រេចជោគជ័យ តាមគោលដៅ និង វត្ថុបំណងដែល សាកលវិទ្យាល័យកម្ពុជា និង ម្ចាស់អំណោយ រំពឹងទុក ។

នៅទីបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះគណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ពីសេសគឺ បណ្ឌិត **ហារុហ៊ីសា ហាន់ដា** និង **គណៈប្រតិភូ** ដែលបានអញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់ “ **ជ័យលាភីអាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន ~ និស្សិតពូកែ** ” ក្នុងពេលព្រឹកនេះ ។

សូមគោរពជូនពរ **គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ឯកឧត្តម លោកជំទាវ អស់លោក - លោកស្រី និង ក្មួយៗជានិស្សិតទាំងអស់** អោយបានប្រកបដោយជោគជ័យ សេរីមង្គល និង វិបុលសុខ គ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ !